# អនុក្រឹត្យ

# ស្តីពី

# ភារកិច្ច និងរចនាសម្ព័ន្ធទូទៅ
# នៃកងរាជអាវុធហត្ថ

**រាជរដ្ឋាភិបាលកម្ពុជា**

**អនុក្រឹត្យ/៧៧ អនក្រ/២១ ធ្នូ ១៩៩៤/ស្តីពីការកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ**

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០២ ខែកក្កដា ១៩៩៣ ស្តីពីការតែងតាំង សហអគ្គមេបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៤ ស្តីពីការកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ
- បានឃើញយោបល់របស់ទីប្រឹក្សាខាងកិច្ចការពារជាតិ និងក្រុមប្រឹក្សាអ្នកច្បាប់ អមនាយករដ្ឋមន្ត្រី

## សំរេច ·

**មាត្រា១:** កងរាជអាវុធហត្ថ ដែលគ្រប់គ្រងដោយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទនោះ ត្រូវឋិតនៅក្រោមបញ្ជាផ្ទាល់ របស់នាយករដ្ឋមន្ត្រី។

**មាត្រា២:** នាយករដ្ឋមន្ត្រី ជាអ្នកកំណត់ក្របខ័ណ្ឌសកម្មភាពទូទៅ។ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ អ្នកទទួលខុសត្រូវ លើផ្នែករដ្ឋបាលទូទៅ និងជាអ្នកផ្តល់សំភារៈ និងថវិកា សំរាប់ផ្គត់ផ្គង់កងរាជ អាវុធហត្ថ។ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ មានភារៈគ្រប់គ្រងសំដៅហ្វឹកហ្វឺន កសាងរៀបចំ កងរាជអាវុធហត្ថ អោយរីកចំរើន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការរ៉ាប់រងតួនាទី និងភារកិច្ច របស់ខ្លួន។

**មាត្រា៣:** កងរាជអាវុធហត្ថ ជាផ្នែកមួយរបស់កងយោធពលខេមរភូមិន្ទ ដែលមានស្វ័យភាព ក្នុងកិច្ច អនុវត្តច្បាប់ កងរាជអាវុធហត្ថ មានសកម្មភាពផ្នែក ប៉ូលីសដែលមានឧបនិស្ស័យជាអន្តរក្រសួង ។ សមត្ថកិច្ចកងរាជអាវុធហត្ថ ត្រូវអនុវត្តពេញផ្ទៃប្រទេសទាំងមូល ទៅលើពលរដ្ឋស៊ីវិល ព្រមទាំងទៅលើ យោធា ក្នុងជួរកងទ័ពផង ។

**មាត្រា៤:** កងរាជអាវុធហត្ថមានភារកិច្ច:

ក-រ៉ាប់រងសកម្មភាពខាងប៉ូលីសរដ្ឋបាល:

- រក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- រ៉ាប់រងអោយមានការគោរពច្បាប់ និងបទបញ្ជាទាំងឡាយ
- ផ្តល់ពត៌មាន និងជួយសង្គ្រោះពលរដ្ឋស៊ីវិល

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថ អនុវត្តតាមបញ្ជារបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ។

ខ- រ៉ាប់រងសកម្មភាពខាងប៉ូលីសតុលាការ:

- ពិនិត្យកត់ត្រានូវឧក្រិដ្ឋកម្ម និងទោសកម្ម
- ធ្វើកំណត់ហេតុអំពីបទល្មើស
- ប្រមូលផ្តុំភស្តុតាងផ្សេងៗ
- ស្រាវជ្រាវរាវរកអ្នកប្រព្រឹត្តបទល្មើស ដើម្បីបញ្ជូនខ្លួនទៅតុលាការ តាមដីកាតុលាការ
- ទទួលបន្ទុកអនុវត្តតាមដីកាផ្ទេរអំណាច ពីចៅក្រមស៊ើបសួរ

ក្នុងក្របខ័ណ្ឌនៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជារបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ អង្គការ អយ្យការ និងអាជ្ញាធរតុលាការមានសមត្ថកិច្ច ។

គ- បំពេញបេសកកម្ម ដែលមានលក្ខណៈពិសេសខាងយោធា:

- ទទួលបន្ទុករក្សាសុវត្ថិភាព និងបំពេញតួនាទី ជាកងកិត្តិយស ជាប្រយោជន៍ដល់ស្ថាប័នរាជរដ្ឋាភិបាល និងអាជ្ញាធរជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ។
- ការពារទីតាំងយោធា

- កិច្ចការប៉ូលីសយោធា នៅក្នុង និងក្រៅទីតាំងកងទ័ព

ក្នុងក្របខ័ណ្ឌ នៃភារកិច្ចនេះ កងរាជអាវុធហត្ថអនុវត្តតាមបញ្ជា របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងអាជ្ញាធរយោធាមានសមត្ថកិច្ច ។

ឃ- ផ្តល់កំលាំងទៅជួយក្រសួងនានា ដែលបានស្នើសុំតាមសេចក្តីត្រូវការជាចាំបាច់ ។

**មាត្រា៥:** កងរាជអាវុធហត្ថ អាចនឹងទទួលបេសកកម្មផ្នែកប៉ូលីស ពិសេសបន្ថែមដោយអនុលោមតាមអនុក្រឹត្យក្នុងបច្ឆាកាល ។

**មាត្រា៦:** រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថមាន:

- អធិការដ្ឋានកងរាជអាវុធហត្ថ ទទួលខុសត្រូវដោយអធិការមួយរូប និងអធិការរងមួយរូប ។
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ទទួលខុសត្រូវដោយមេបញ្ជាការមួយរូប និងមេបញ្ជាការរងមួយរូប

**មាត្រា៧:** អធិការដ្ឋានកងរាជអាវុធហត្ថ

អធិការ និងអធិការរងកងរាជអាវុហត្ថ មានភារកិច្ចបំពេញបេសកកម្មត្រួតពិនិត្យ សិក្សា និងផ្តល់ ពត៌មាន ។ អធិការ និងអធិការរងកងរាជអាវុធហត្ថ ត្រូវស្ថិតនៅក្រោមបញ្ជានាយករដ្ឋមន្ត្រីផ្ទាល់ ដែលជាអ្នកកំណត់បេសកកម្ម ។

អធិការ និងអធិការរងកងរាជអាវុធហត្ថ ជាទីប្រឹក្សាអចិន្ត្រៃយ៏របស់នាយករដ្ឋមន្ត្រី។ ក្នុងករណីនេះ អធិការកងរាជអាវុធហត្ថ តំរូវផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រី នូវគំរោងស្តីពីអនាគត ផ្នែករចនាសម្ព័ន្ធ និងមុខងាររបស់កងរាជអាវុធហត្ថ។ អធិការកងរាជអាវុហត្ថ តោងតែតាមពិនិត្យមើលដោយផ្ទាល់ នូវកិច្ចប្រតិបត្តិ ការងារ និងការប្រើប្រាស់បុគ្គលិកកងរាជអាវុធហត្ថ អោយសមស្របតាមក្បួនច្បាប់ ។

**មាត្រា៨:** បញ្ជាការដ្ឋានកងរាជអាវុធហត្ថ

បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ដឹកនាំដោយមេបញ្ជាការ ថ្នាក់ឧត្តមសេនីយ និងមេបញ្ជាការរងមួយរូប មានភារកិច្ច:

- ចងក្រងបទបញ្ញត្តិការងារទូទៅ និងតាមពិនិត្យការអនុវត្តដោយមានទំនាក់ទំនងជាមួយក្រសួង ពាក់ព័ន្ធ ដូចជាក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធមិជាដើម ។
- ផ្តល់ពត៌មានដល់នាយករដ្ឋមន្ត្រី អំពីមធ្យោបាយគ្រប់បែបយ៉ាង ដែលមានភាពបំរើការងារបាន ។

- ដោះស្រាយកែសំរួល ចំពោះបញ្ហាទាក់ទងក្នុងការរៀបចំផ្នែករដ្ឋបាល និងដំណើរការប្រព្រឹត្តទៅ របស់កងរាជអាវុធហត្ថ។

ឋិតនៅក្រោមបញ្ជា របស់មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថមាន៖

- សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ
- កងរាជអាវុធហត្ថផ្ទៃប្រទេស
- កងរាជអាវុធហត្ថចល័ត
- តម្រួតយោធា

**មាត្រា៩៖** សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ៖

សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ ត្រូវទទួលបន្ទុក៖

- រៀបចំកម្មវិធីបង្រៀន
- ហ្វឹកហ្វឺនបុគ្គលិក
- ត្រួតពិនិត្យការហ្វឹកហ្វឺន
- រៀបរៀង និងចងក្រងឯកសារសំរាប់បង្រៀន
- ធ្វើសំណើទៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថ នូវសំភារៈជាចាំបាច់ សំរាប់ដំណើរការសិក្សា អោយមានប្រសិទ្ធភាព។

**មាត្រា១០៖** កងរាជអាវុធហត្ថផ្ទៃប្រទេស៖

កងរាជអាវុធហត្ថផ្ទៃប្រទេស ដែលដាក់អោយអនុវត្តការងារ នៅពេញផ្ទៃព្រះរាជាណាចក្រកម្ពុជា រហូតទៅដល់ថ្នាក់ឃុំ ត្រូវទទួលបន្ទុកបំពេញបេសកកម្ម របស់កងរាជអាវុធហត្ថ ដែលមានចែងក្នុង មាត្រា ៤ នៃ អនុក្រឹត្យនេះ។

សមត្ថកិច្ច នៃកងរាជអាវុធហត្ថផ្ទៃប្រទេស អនុវត្តទៅលើពលរដ្ឋស៊ីវិល និងយោធា។

**មាត្រា១១៖** កងរាជអាវុធហត្ថចល័ត៖

កងរាជអាវុធហត្ថចល័ត ជាកងកំលាំងសំរាប់រ៉ាប់រងអោយមានសណ្តាប់ធ្នាប់ និងប្រយុទ្ធប្រឆាំងនឹងក្រុមប្រដាប់អាវុធខុសច្បាប់។ កងរាជអាវុធហត្ថចល័ត អនុវត្តការងារពេញផ្ទៃប្រទេស តាមការស្នើសុំពី

កងរាជអាវុធហត្ថផ្ទៃប្រទេស ឬតាមសំបុត្រកំណែនពីអាជ្ញាធរមានសមត្ថកិច្ចផ្នែករដ្ឋបាល ឬតុលាការ។ កងរាជអាវុធហត្ថចល័ត ត្រូវត្រៀមខ្លួនជានិច្ច សំរាប់បន្ថែមកំលាំងក្នុងពេលខ្លីបំផុត ទៅជួយកងឯកភាពនៃកងរាជអាវុធហត្ថផ្ទៃប្រទេស។

**មាត្រា១២:** តម្រួតយោធា:

តម្រួតយោធា គឺជាកងកំលាំងមួយ នៃកងរាជអាវុធហត្ថ ដែលមានភារកិច្ចចុះទៅធ្វើការផ្ទាល់ជាមួយនឹងកងទ័ពទាំងបីប្រភេទ នៃកងយោធពលខេមរភូមិន្ទ។ តម្រួតយោធា បំពេញបេសកកម្មនេះក្រោមបញ្ជាអាជ្ញាធរ ដូចមានចែងក្នុងវគ្គ "គ" នៃមាត្រា ៤ នៃអនុក្រឹត្យនេះ។

**មាត្រា១៣:** អធិការ ឬមេបញ្ជាការកងរាជអាវុធហត្ថ អាចស្នើបង្កើន នូវអង្គភាពឯកទេសផ្សេងៗ ទៀត ដើម្បីប្រសិទ្ធភាពការងារ ក្នុងកាលៈទេសៈចាំបាច់។

**មាត្រា១៤:** នាយករដ្ឋមន្ត្រីសម្រេចកំណត់ភារកិច្ចចំនួនជាក់ស្តែង និងការតែងតាំងក្នុងការរៀបចំស្ថាប័នលើសំណើពីមេបញ្ជាការ និងអធិការកងរាជអាវុធហត្ថ ដែលបានពិភាក្សាឬរយោបល់ជាមួយសហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ។

**មាត្រា១៥:** អនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី ១៥ មិថុនា ១៩៩៤ ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយអំពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និងគ្រប់ក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៩៤

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

នរោត្តម រណឫទ្ធិ ហ៊ុន សែន